ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

10_17.7
F2156

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
លេខ......០៦១......អ.ស.ហ.ប្រក

# ប្រកាស
# ស្តីពី
# ការកំណត់កម្រិតសាធនភាពសម្រាប់ក្រុមហ៊ុនធានារ៉ាប់រង

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១៤/០២១ ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ២៧៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការធានារ៉ាប់រង
- យោងតាមការចាំបាច់របស់និយ័តករធានារ៉ាប់រងកម្ពុជា

## **សម្រេច**
## **ជំពូកទី១**
## **បទប្បញ្ញត្តិទូទៅ**

**ប្រការ១ .-**

ប្រកាសនេះ មានគោលបំណងកំណត់កាតព្វកិច្ចរបស់ក្រុមហ៊ុនធានារ៉ាប់រងក្នុងការរក្សាកម្រិតសាធនភាព ឱ្យបានគ្រប់គ្រាន់ និងគ្រប់ពេល ដើម្បីធានាបាននូវសមត្ថភាពក្នុងការបំពេញកាតព្វកិច្ចបំណុលរបស់ក្រុមហ៊ុន។

**ប្រការ២ .-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះក្រុមហ៊ុនធានារ៉ាប់រងទូទៅ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ក្រុមហ៊ុនធានារ៉ាប់រងបន្ត និងក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច ដែលកំពុងធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣ .-**

វាក្យសព្ទដែលប្រើនៅក្នុងប្រកាសនេះ មាននិយមន័យដូចខាងក្រោម៖

- **សាធនភាព** សំដៅដល់សមត្ថភាពរបស់ក្រុមហ៊ុនធានារ៉ាប់រងក្នុងការបំពេញកាតព្វកិច្ចបំណុល។
- **ទ្រព្យសកម្មជាប់កាតព្វកិច្ច** សំដៅដល់ទ្រព្យសកម្មទាំងឡាយណាដែលជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ បទប្បញ្ញត្តិ កិច្ចសន្យា ឬកាតព្វកិច្ចផ្សេងទៀត ដែលរារាំងក្រុមហ៊ុនក្នុងការជម្រះបញ្ជី លក់ ផ្ទេរ ឬចាត់ចែងទ្រព្យសកម្មទាំងនេះ។
- **កាលបរិច្ឆេទបិទបញ្ជីគណនេយ្យ** សំដៅដល់កាលបរិច្ឆេទ ដែលត្រូវបិទបញ្ជីគណនេយ្យដោយត្រូវបានកំណត់នៅថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំនីមួយៗ។
- **ក្រុមហ៊ុនធានារ៉ាប់រង** សំដៅដល់ក្រុមហ៊ុនធានារ៉ាប់រងទូទៅ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ក្រុមហ៊ុនធានារ៉ាប់រងបន្ត និងក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច។
- **ប្រាក់បម្រុងគណិតវិទ្យា** សំដៅដល់ប្រាក់បម្រុងដែលគណនាដោយប្រើប្រាស់ **"វិធីសាស្ត្រវាយតម្លៃបុព្វលាភធានារ៉ាប់រងដុល (Gross Premium Valuation - GPV)"** ដែលក្រុមហ៊ុនធានារ៉ាប់រងត្រូវរក្សាទុក សម្រាប់ទូទាត់សំណងធានារ៉ាប់រងនិងចំណាយដែលកើតឡើងពីកិច្ចសន្យាធានារ៉ាប់រងរយៈពេលច្រើនជាង ១ (មួយ) ឆ្នាំ។
- **ប្រាក់ធានារ៉ាប់រងតាមហានិភ័យ** (Sum at Risk) សំដៅដល់ប្រាក់បន្ថែមលើប្រាក់បម្រុងបច្ចេកទេសធានារ៉ាប់រង សម្រាប់គណនាសាធនភាពតម្រូវ ក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព ឬពិការអចិន្ត្រៃយ៍។ ប្រាក់ធានារ៉ាប់រងតាមហានិភ័យសម្រាប់ផលិតផលធានា-រ៉ាប់រងរងបន្ថែមវេជ្ជសាស្ត្រត្រូវបានកំណត់ឱ្យស្មើសូន្យ។

- **ដើមទុនផ្ទាល់របស់ម្ចាស់ហ៊ុន** សំដៅដល់ដើមទុនជាសាច់ប្រាក់របស់ភាគទុនិករបស់ក្រុមហ៊ុនធានារ៉ាប់រង។

## ជំពូកទី២

## កម្រិតសាធនភាព

**ប្រការ៤.-**

កម្រិតសាធនភាពរបស់ក្រុមហ៊ុនធានារ៉ាប់រង គឺជាផលធៀបនៃទ្រព្យសកម្មសុទ្ធ និងសាធនភាពតម្រូវរបស់ក្រុមហ៊ុនធានារ៉ាប់រង។ ក្រុមហ៊ុនធានារ៉ាប់រង ត្រូវរក្សាកម្រិតសាធនភាពមិនឱ្យតិចជាង ១២០ (មួយរយម្ភៃ) ភាគរយ នៅក្នុងអំឡុងពេលនៃដំណើរការអាជីវកម្ម ។

ក្នុងករណីក្រុមហ៊ុនធានារ៉ាប់រងមានកម្រិតសាធនភាពប្រចាំត្រីមាស ឬប្រចាំឆ្នាំ តិចជាង ១២០ (មួយរយម្ភៃ) ភាគរយ ប៉ុន្តែច្រើនជាងឬស្មើ ១០០ (មួយរយ) ភាគរយ ក្រុមហ៊ុនធានារ៉ាប់រង ត្រូវរៀបចំផែនការស្តារកម្រិតសាធនភាពឡើងវិញ ដែលផែនការនោះត្រូវមានការសម្រេចពីក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន និងត្រូវស្នើសុំការអនុញ្ញាតពី **ន.ធ.ក.** ក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីថ្ងៃផ្តល់របាយការណ៍ប្រចាំត្រីមាស ឬប្រចាំឆ្នាំ។

ក្នុងករណីក្រុមហ៊ុនធានារ៉ាប់រងមានកម្រិតសាធនភាពប្រចាំត្រីមាស ឬប្រចាំឆ្នាំ តិចជាង ១០០ (មួយរយ) ភាគរយ ក្រុមហ៊ុនធានារ៉ាប់រងត្រូវបំពេញកម្រិតសាធនភាពជាបន្ទាន់ និងត្រូវរងទណ្ឌកម្មខាងវិន័យ ដូចខាងក្រោម៖

- បញ្ឈប់ការលក់បណ្ណសន្យារ៉ាប់រងថ្មី
- បញ្ឈប់ការអនុញ្ញាតសកម្មភាពអាជីវកម្មថ្មី ឬការទិញលក់ផ្សេងៗ
- បញ្ឈប់សកម្មភាពផ្សេងៗរបស់ក្រុមហ៊ុនធានារ៉ាប់រង
- ដាក់កំហិតលើការលក់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន
- ផ្ទេរបណ្ណសន្យារ៉ាប់រងដែលមិនទាន់ផុតកំណត់មួយផ្នែក ឬទាំងស្រុងរបស់ក្រុមហ៊ុន
- បញ្ឈប់មុខងាររបស់អគ្គនាយកក្រុមហ៊ុនធានារ៉ាប់រង
- តែងតាំងអភិបាលបណ្តោះអាសន្នដើម្បីស្តារក្រុមហ៊ុន
- ដកហូតអាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រង និងជម្រះបញ្ជីក្រុមហ៊ុន។

**ប្រការ៥ .-**

ទ្រព្យសកម្មសុទ្ធរបស់ក្រុមហ៊ុនធានារ៉ាប់រង ត្រូវបានគណនាដោយយកសមតុល្យទ្រព្យសកម្មសរុបរបស់ក្រុមហ៊ុន ដកបំណុលសរុបរបស់ក្រុមហ៊ុននិងដកទ្រព្យសកម្មមួយចំនួនទៀតរបស់ក្រុមហ៊ុន ដូចខាងក្រោម៖

- គណនីត្រូវទទួលដែលមានរយៈពេលលើស ១៨០ថ្ងៃ

- ប្រាក់បុរេប្រទាន និងចំណាយបង់មុន
- ប្រាក់កម្ចីទៅឱ្យភាគីពាក់ព័ន្ធ
- ថ្លៃដើមទិញពន្យា
- ប្រាក់អតិរេកពីការវាយតម្លៃឡើងវិញនៃអចលនទ្រព្យ
- ទ្រព្យសកម្មអរូបិយ ដូចមានកំណត់ក្នុងស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជាទី៣៨ និងស្តង់ដាររបាយការណ៍ទាក់ទងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាទី៣ អំពីមូលនិធិពាណិជ្ជកម្ម
- ទ្រព្យសកម្មជាប់កាតព្វកិច្ច។

**ប្រការ៦ ..**

សាធនភាពតម្រូវរបស់ក្រុមហ៊ុនធានារ៉ាប់រងទូទៅ និងក្រុមហ៊ុនធានារ៉ាប់រងបន្តចំពោះការធានារ៉ាប់រងទូទៅត្រូវបានគណនាតាមវិធីសាស្ត្រ ដូចខាងក្រោម៖

១. វិធីសាស្ត្រសំណងធានារ៉ាប់រងសុទ្ធ សាធនភាពតម្រូវស្មើនឹង (ក) + (ខ)

(ក). ២៦ (ម្ភៃប្រាំមួយ) ភាគរយ នៃសំណងធានារ៉ាប់រងសុទ្ធដែលបានកើតឡើងជាមធ្យម ចំពោះប្រាក់សំណងធានារ៉ាប់រងសុទ្ធដែលបានកើតឡើងជាមធ្យមតិចជាង ឬស្មើ ៣៥ (សាមសិបប្រាំ) លានដុល្លារអាមេរិក។ សំណងធានារ៉ាប់រងសុទ្ធដែលបានកើតឡើងជាមធ្យម ស្មើនឹងសំណងធានារ៉ាប់រងដុលដែលបានទូទាត់ ដក សំណងធានារ៉ាប់រងដែលបានទូទាត់ត្រឡប់ពីការធានា-រ៉ាប់រងបន្ត បូក បម្រែបម្រួលនៃប្រាក់បម្រុងសម្រាប់សំណងធានារ៉ាប់រងមិនទាន់ទូទាត់សុទ្ធជាមធ្យមក្នុងរយៈពេល ៣ (បី) ឆ្នាំ។

(ខ). ២៣ (ម្ភៃបី) ភាគរយ នៃសំណងធានារ៉ាប់រងសុទ្ធដែលបានកើតឡើងជាមធ្យម ចំពោះប្រាក់សំណងធានារ៉ាប់រងសុទ្ធដែលបានកើតឡើងជាមធ្យមច្រើនជាង ៣៥ (សាមសិបប្រាំ) លានដុល្លារអាមេរិក។

ក្នុងករណីសំណងសុទ្ធដែលបានកើតឡើង តិចជាង ៥០ (ហាសិប) ភាគរយ នៃសំណងដុលដែលបានកើតឡើង ក្រុមហ៊ុនធានារ៉ាប់រងទូទៅ និងក្រុមហ៊ុនធានារ៉ាប់រងបន្តចំពោះការធានារ៉ាប់រងទូទៅ ត្រូវកំណត់យកសំណងធានារ៉ាប់រងសុទ្ធដែលបានកើតឡើង ស្មើនឹង ៥០ (ហាសិប) ភាគរយ នៃសំណងធានារ៉ាប់រងដុលដែលបានកើតឡើង។

២. វិធីសាស្ត្របុព្វលាភធានារ៉ាប់រងសុទ្ធ សាធនភាពតម្រូវស្មើនឹង (ក) + (ខ)

(ក). ១៨ (ដប់ប្រាំបី) ភាគរយ នៃបុព្វលាភធានារ៉ាប់រងសុទ្ធ ចំពោះបុព្វលាភធានារ៉ាប់រងសុទ្ធមានចំនួនតិចជាង ឬស្មើ ៥០ (ហាសិប) លានដុល្លារអាមេរិក។ បុព្វលាភធានារ៉ាប់រងសុទ្ធ ស្មើនឹងបុព្វលាភធានារ៉ាប់រងដុល ដក បុព្វលាភធានារ៉ាប់រងបន្ត។

(ខ). ១៦ (ដប់ប្រាំមួយ) ភាគរយ នៃបុព្វលាភធានារ៉ាប់រងសុទ្ធ ចំពោះបុព្វលាភធានារ៉ាប់រងសុទ្ធមាន

ចំនួនច្រើនជាង ៥០ (ហាសិប) លានដុល្លារអាមេរិក។

ក្នុងករណីបុព្វលាភធានារ៉ាប់រងសុទ្ធ តិចជាង ៥០ (ហាសិប) ភាគរយនៃបុព្វលាភធានារ៉ាប់រងដុល ក្រុមហ៊ុនធានារ៉ាប់រងទូទៅ និងក្រុមហ៊ុនធានារ៉ាប់រងបន្តចំពោះការធានារ៉ាប់រងទូទៅ ត្រូវកំណត់យកបុព្វលាភធានារ៉ាប់រងសុទ្ធ ស្មើនឹង ៥០ (ហាសិប) ភាគរយ នៃបុព្វលាភធានារ៉ាប់រងដុល។

សាធនភាពតម្រូវនេះ ត្រូវបានកំណត់ដោយយកចំនួនដែលធំជាងរវាងលទ្ធផលនៃការគណនាតាមវិធីសាស្ត្រណាមួយខាងលើ។

**ប្រការ៧ ._**

សាធនភាពតម្រូវរបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត និងក្រុមហ៊ុនធានារ៉ាប់រងបន្តចំពោះការធានារ៉ាប់រងអាយុជីវិត ត្រូវស្មើនឹង (ក) + (ខ)៖

(ក).៤ (បួន) ភាគរយនៃប្រាក់បម្រុងគណិតវិទ្យាសុទ្ធ។ ប្រាក់បម្រុងគណិតវិទ្យាសុទ្ធ ស្មើនឹងប្រាក់បម្រុងគណិតវិទ្យាដុល ដក ប្រាក់បម្រុងគណិតវិទ្យា តាមរយៈការធានារ៉ាប់រងបន្ត។

ក្នុងករណីប្រាក់បម្រុងគណិតវិទ្យាសុទ្ធ តិចជាង ៨៥ (ប៉ែតសិបប្រាំ) ភាគរយនៃប្រាក់បម្រុងគណិតវិទ្យាដុល ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត និងក្រុមហ៊ុនធានារ៉ាប់រងបន្តចំពោះការធានារ៉ាប់រងអាយុជីវិត ត្រូវកំណត់យកប្រាក់បម្រុងគណិតវិទ្យាសុទ្ធ ស្មើនឹង ៨៥ (ប៉ែតសិបប្រាំ)ភាគរយ នៃប្រាក់បម្រុងគណិតវិទ្យាដុល។

(ខ).០,៣ (សូន្យក្បៀសបី) ភាគរយ នៃប្រាក់ធានារ៉ាប់រងតាមហានិភ័យសុទ្ធ។ ប្រាក់ធានារ៉ាប់រងតាមហានិភ័យសុទ្ធ ស្មើនឹងប្រាក់ធានារ៉ាប់រងតាមហានិភ័យដុល ដក ប្រាក់ធានារ៉ាប់រងតាមហានិភ័យតាមរយៈការធានារ៉ាប់រងបន្ត។ ប្រាក់ធានារ៉ាប់រងតាមហានិភ័យ ត្រូវបានគណនាដោយយកប្រាក់ដែលត្រូវបានធានារ៉ាប់រង ដក ប្រាក់បម្រុងគណិតវិទ្យា។

ក្នុងករណីប្រាក់ធានារ៉ាប់រងតាមហានិភ័យសុទ្ធ តិចជាង ៥០ (ហាសិប) ភាគរយ នៃប្រាក់ធានារ៉ាប់រងតាមហានិភ័យដុល ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត និងក្រុមហ៊ុនធានារ៉ាប់រងបន្តចំពោះការធានារ៉ាប់រងអាយុជីវិត ត្រូវកំណត់យកប្រាក់ធានារ៉ាប់រងតាមហានិភ័យសុទ្ធ ស្មើនឹង ៥០ (ហាសិប) ភាគរយ នៃប្រាក់ធានារ៉ាប់រងតាមហានិភ័យដុល។

**ប្រការ៨ ._**

សាធនភាពតម្រូវរបស់ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច ត្រូវបានគណនាស្មើនឹង ២៥ (ម្ភៃប្រាំ) ភាគរយនៃបុព្វលាភធានារ៉ាប់រងសុទ្ធ។

ក្នុងករណីបុព្វលាភធានារ៉ាប់រងសុទ្ធ តិចជាង ៥០ (ហាសិប) ភាគរយនៃបុព្វលាភធានារ៉ាប់រងដុល ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចត្រូវកំណត់យកបុព្វលាភធានារ៉ាប់រងសុទ្ធ ស្មើនឹង ៥០ (ហាសិប) ភាគរយ នៃបុព្វលាភធានារ៉ាប់រងដុល។

**ប្រការ៩ ._**

ក្នុងការគណនាសាធនភាពតម្រូវប្រចាំត្រីមាស ក្រុមហ៊ុនធានារ៉ាប់រងទូទៅ ក្រុមហ៊ុនធានារ៉ាប់រងបន្តចំពោះការធានារ៉ាប់រងទូទៅ និងក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច ត្រូវប្រើប្រាស់ទិន្នន័យប្រចាំត្រីមាស ក្នុងរយៈពេល ៤ (បួន) ត្រីមាសចុងក្រោយ។ ដោយឡែកចំពោះវិធីសាស្ត្រសំណងធានារ៉ាប់រងសុទ្ធ ក្រុមហ៊ុនធានា-រ៉ាប់រងទូទៅ និងក្រុមហ៊ុនធានារ៉ាប់រងបន្តចំពោះការធានារ៉ាប់រងទូទៅ ត្រូវប្រើប្រាស់ទិន្នន័យប្រចាំត្រីមាស ក្នុងរយៈពេល ១២ (ដប់ពីរ) ត្រីមាសចុងក្រោយ។

ក្នុងការគណនាសាធនភាពតម្រូវប្រចាំឆ្នាំ ក្រុមហ៊ុនធានារ៉ាប់រង ត្រូវប្រើប្រាស់ទិន្នន័យរងសវនកម្មឆ្នាំចុងក្រោយ។ ដោយឡែកចំពោះវិធីសាស្ត្រសំណងធានារ៉ាប់រងសុទ្ធ ក្រុមហ៊ុនធានារ៉ាប់រងទូទៅ និងក្រុមហ៊ុនធានារ៉ាប់រងបន្តចំពោះការធានារ៉ាប់រងទូទៅ ត្រូវប្រើប្រាស់ទិន្នន័យរងសវនកម្មប្រចាំឆ្នាំក្នុងរយៈពេល ៣ (បី) ឆ្នាំចុងក្រោយ។

**ប្រការ១០ ._**

ក្នុងករណី លទ្ធផលនៃការគណនាសាធនភាពតម្រូវនេះ តិចជាងសាធនភាពតម្រូវអប្បបរមា ក្រុមហ៊ុនត្រូវកំណត់យកចំនួនប្រាក់សាធនភាពតម្រូវអប្បបរមាជាសាធនភាពតម្រូវរបស់ក្រុមហ៊ុន។

**ប្រការ១១ ._**

សាធនភាពតម្រូវអប្បបរមារបស់ក្រុមហ៊ុនធានារ៉ាប់រង គឺជាចំនួនប្រាក់ ៥០ (ហាសិប) ភាគរយ នៃដើមទុនអប្បបរមា ដែលក្រុមហ៊ុនធានារ៉ាប់រងត្រូវរក្សាជាសាច់ប្រាក់នៅក្នុងធនាគារពាណិជ្ជក្នុងស្រុក ដោយមិនឱ្យលើសពី ៣០ (សាមសិប) ភាគរយក្នុងធនាគារពាណិជ្ជមួយ នៅក្នុងអំឡុងពេលនៃដំណើរការអាជីវកម្ម។

ក្នុងករណីដែលប្រាក់សាធនភាពតម្រូវអប្បបរមានេះ ត្រូវបានប្រើប្រាស់នៅសល់ក្រោមកម្រិតកំណត់ខាងលើ ក្រុមហ៊ុនធានារ៉ាប់រងត្រូវបំពេញបង្គ្រប់វិញ នៅក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ គិតចាប់ថ្ងៃទទួលបានលិខិតជូនដំណឹងពី **ន.ធ.ក.**។

**ប្រការ១២ ._**

ក្នុងករណីក្រុមហ៊ុនធានារ៉ាប់រងតម្រូវឱ្យមានប្រាក់សាធនភាពតម្រូវច្រើនជាងប្រាក់សាធនភាពតម្រូវអប្បបរមា ក្រុមហ៊ុនមានកាតព្វកិច្ចបង្កើនដើមទុនផ្ទាល់របស់ម្ចាស់ហ៊ុនក្នុងរយៈពេល ៣ (បី) ខែ គិតចាប់ពីកាលបរិច្ឆេទជូនដំណឹងរបស់ **ន.ធ.ក.** និងត្រូវស្នើសុំការអនុញ្ញាតក្នុងការបង្កើនដើមទុននេះពី **ន.ធ.ក.**។

**ប្រការ១៣ ._**

ក្នុងករណីក្រុមហ៊ុនធានារ៉ាប់រងមានសាធនភាពតម្រូវច្រើនជាងសាធនភាពតម្រូវអប្បបរមា ក្រុមហ៊ុនអាចវិនិយោគប្រាក់ដែលលើសនេះ តាមខ្លឹមសារប្រកាសស្តីពីការអនុញ្ញាតលើការវិនិយោគសម្រាប់ក្រុមហ៊ុនធានារ៉ាប់រង។

## ជំពូកទី៣

## ដើមទុន

**ប្រការ១៤ .-**

ក្រុមហ៊ុនធានារ៉ាប់រងទូទៅ ឬក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ត្រូវមានដើមទុនអប្បបរមាដែលជាដើមទុនផ្ទាល់របស់ម្ចាស់ហ៊ុន ជាប្រាក់រៀលចំនួនសមមូលនឹង **៥ ០០០ ០០០ (ប្រាំលាន) អេសឌីអរ** តាមអត្រាពេលចេញអាជ្ញាបណ្ណ។

ក្រុមហ៊ុនធានារ៉ាប់រងបន្ត ត្រូវមានដើមទុនអប្បបរមាដែលជាដើមទុនផ្ទាល់របស់ម្ចាស់ហ៊ុនជាប្រាក់រៀលចំនួនសមមូលនឹង **៥ ០០០ ០០០ (ប្រាំលាន) អេសឌីអរ** តាមអត្រាពេលចេញអាជ្ញាបណ្ណ សម្រាប់ការធានា-រ៉ាប់រងបន្តទូទៅ ឬការធានារ៉ាប់រងបន្តអាយុជីវិត។

ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច ត្រូវមានដើមទុនអប្បបរមាដែលជាដើមទុនផ្ទាល់របស់ម្ចាស់ហ៊ុន ចំនួន **២ ០០០ ០០០ ០០០ (ពីរប៊ីលាន)** រៀល។

**ប្រការ១៥ .-**

ដើមទុនអប្បបរមា ត្រូវបានកំណត់ដូចខាងក្រោម៖

- ១០ (ដប់) ភាគរយ នៃដើមទុនអប្បបរមា ជាប្រាក់តម្កល់ធានាអាជីវកម្មនៅក្នុងគណនីរបស់ ន.ធ.ក.
- ៥០ (ហាសិប) ភាគរយ នៃដើមទុនអប្បបរមា ជាសាច់ប្រាក់ធានាសាធនភាពតម្រូវអប្បបរមា នៅក្នុងធនាគារពាណិជ្ជក្នុងស្រុក ដោយមិនឱ្យលើសពី ៣០ភាគរយក្នុងធនាគារពាណិជ្ជមួយ
- ៤០ (សែសិប) ភាគរយ នៃដើមទុនអប្បបរមា ជាអចលនទ្រព្យប្រើប្រាស់ផ្ទាល់ដោយក្រុមហ៊ុនដែលត្រូវស្នើសុំការអនុញ្ញាតជាមុនពី **ន.ធ.ក.** ឬជាសាច់ប្រាក់។

**ប្រការ១៦ .-**

ក្រុមហ៊ុនធានារ៉ាប់រងមានកាតព្វកិច្ចបង្កើនដើមទុនផ្ទាល់របស់ម្ចាស់ហ៊ុន ក្នុងរយៈពេលយ៉ាងយូរ ៦ (ប្រាំមួយ)ខែ គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យប្រចាំឆ្នាំ ដោយសុំការអនុញ្ញាតពី **ន.ធ.ក.** ក្នុងករណីក្រុមហ៊ុនធានារ៉ាប់រងមានសមតុល្យមូលធនផ្ទាល់ តិចជាងដើមទុនអប្បបរមាដូចមានកំណត់ក្នុងប្រការ ១៥ ខាងលើ។

ដើមទុនផ្ទាល់របស់ម្ចាស់ហ៊ុន មិនអាចជាប្រាក់កម្ចីពីសាធារណៈជន ឬធនាគារពាណិជ្ជ ឬស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត ឬកម្ចីផ្សេងទៀត និងមិនមែនជាទ្រព្យសកម្មជាប់កាតព្វកិច្ចនោះទេ។ សមតុល្យមូលធនផ្ទាល់ ត្រូវបានគណនាដោយបូកចំនួនដើមទុនផ្ទាល់របស់ម្ចាស់ហ៊ុន ជាមួយប្រាក់ចំណេញរក្សាទុក។

**ប្រការ១៧ .-**

ក្រុមហ៊ុនធានារ៉ាប់រង ត្រូវស្នើសុំការអនុញ្ញាតជាមុនពី **ន.ធ.ក.** លើការបែងចែកភាគលាភជូនភាគទុនិក។

## ជំពូកទី៤

## ភាតព្វកិច្ចផ្តល់របាយការណ៍

**ប្រការ១៨ .-**

ក្រុមហ៊ុនធានារ៉ាប់រង ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។

**ប្រការ១៩ .-**

ក្រុមហ៊ុនធានារ៉ាប់រង ត្រូវផ្តល់របាយការណ៍ប្រចាំឆ្នាំស្តីពីការគណនាកម្រិតសាធនភាព និងដើមទុនមក **ន.ធ.ក.** ឱ្យបានមុនថ្ងៃទី៣១ ខែមីនា នៃឆ្នាំបន្ទាប់ ក្នុងទម្រង់តាមការកំណត់របស់ **ន.ធ.ក.**។

**ប្រការ២០ .-**

ក្រុមហ៊ុនធានារ៉ាប់រង ត្រូវផ្តល់របាយការណ៍ប្រចាំត្រីមាសស្តីពីការគណនាកម្រិតសាធនភាព និងដើមទុនមក **ន.ធ.ក.** ឱ្យបានមុនថ្ងៃទី១៥ នៃខែទី១ នៃត្រីមាសបន្ទាប់ ក្នុងទម្រង់តាមការកំណត់របស់ **ន.ធ.ក.**។

**ប្រការ២១ .-**

ក្រុមហ៊ុនធានារ៉ាប់រង ត្រូវផ្តល់របាយការណ៍ប្រចាំខែអំពីរបាយការណ៍គណនីសាធនភាពតម្រូវចេញដោយធនាគារពាណិជ្ជក្នុងស្រុក មក **ន.ធ.ក.** ឱ្យបានមុនថ្ងៃទី១៥ នៃខែបន្ទាប់។

## ជំពូកទី៥

## ទោសប្បញ្ញត្តិ

**ប្រការ២២ .-**

ក្រុមហ៊ុនធានារ៉ាប់រង ដែលមិនអនុវត្តតាមបទប្បញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលរងវិធានការរដ្ឋបាលពី **ន.ធ.ក.** ដូចខាងក្រោម ៖

- ការព្រមាន
- ការដឹកនាំកែតម្រង់
- ការដាក់កំហិតលើសកម្មភាពអាជីវកម្ម
- ការដកហូតអាជ្ញាបណ្ណ ឬវិញ្ញាបនបត្រ ឬលិខិតអនុញ្ញាត។

**ប្រការ២៣ .-**

ត្រូវទទួលរងវិធានការរដ្ឋបាលដូចមានចែងក្នុងប្រការ ២២ និង/ឬ ត្រូវផាកពិន័យជាប្រាក់ពី ២០ ០០០ ០០០(ម្ភៃលាន) រៀល ទៅ ៥០ ០០០ ០០០(ហាសិបលាន) រៀល ដោយ **ន.ធ.ក.** ចំពោះ ក្រុមហ៊ុនធានារ៉ាប់រងដែលមិនបានរៀបចំ និងផ្តល់ផែនការស្តារកម្រិតសាធនភាពឡើងវិញ ដូចមានចែងក្នុងប្រការ៤ នៃប្រកាសនេះ។

ត្រូវទទួលរងវិធានការរដ្ឋបាលដូចមានចែងក្នុងប្រការ ២២ និង/ឬ ត្រូវផាកពិន័យជាប្រាក់ពី ១០ ០០០ ០០០(ដប់លាន) រៀល ទៅ ២០ ០០០ ០០០(ម្ភៃលាន) រៀល ដោយ **ន.ធ.ក.** ចំពោះក្រុមហ៊ុនធានារ៉ាប់រងដែលយឺតយ៉ាវក្នុងការផ្តល់ផែនការស្តារកម្រិតសាធនភាពឡើងវិញ ចាប់ពី ១(មួយ)ថ្ងៃ ដល់ ៣០ (សាមសិប) ថ្ងៃ។ ក្នុងករណីយឺតយ៉ាវមានរយៈពេលលើសពី ៣០ (សាមសិប) ថ្ងៃ ក្រុមហ៊ុនត្រូវទទួលការផាកពិន័យជាប្រាក់ចំនួនទ្វេដងនៃប្រាក់ផាកពិន័យលើកមុន។

**ប្រការ២៤ ._**

ត្រូវទទួលរងវិធានការរដ្ឋបាលដូចមានចែងក្នុងប្រការ២២ និង/ឬ ត្រូវផាកពិន័យជាប្រាក់ពី ២០ ០០០ ០០០(ម្ភៃលាន) រៀល ទៅ១០០ ០០០ ០០០(មួយរយលាន) រៀល ដោយ **ន.ធ.ក.** ចំពោះក្រុមហ៊ុនធានារ៉ាប់រងដែលមិនបានបំពេញបង្គ្រប់ប្រាក់សាធនភាពតម្រូវអប្បបរមា តាមកាលកំណត់ ដូចមានចែងក្នុងប្រការ១១ នៃប្រកាសនេះ។

ត្រូវទទួលរងវិធានការរដ្ឋបាលដូចមានចែងក្នុងប្រការ២២ និង/ឬ ត្រូវផាកពិន័យជាប្រាក់ពី ១០ ០០០ ០០០(ដប់លាន) រៀល ទៅ ៥០ ០០០ ០០០(ហាសិបលាន) រៀល ដោយ **ន.ធ.ក.** ចំពោះក្រុមហ៊ុនធានារ៉ាប់រងដែលយឺតយ៉ាវក្នុងការបំពេញបង្គ្រប់ប្រាក់សាធនភាពតម្រូវអប្បបរមា ចាប់ពី ១(មួយ) ថ្ងៃ ដល់ ៣០(សាមសិប) ថ្ងៃ។ ក្នុងករណីយឺតយ៉ាវមានរយៈពេលលើសពី ៣០(សាមសិប) ថ្ងៃ ក្រុមហ៊ុនត្រូវទទួលការផាកពិន័យជាប្រាក់ចំនួនទ្វេដងនៃប្រាក់ផាកពិន័យលើកមុន។

**ប្រការ២៥ ._**

ត្រូវទទួលរងវិធានការរដ្ឋបាលដូចមានចែងក្នុងប្រការ២២ និង/ឬ ត្រូវផាកពិន័យជាប្រាក់ពី ២០ ០០០ ០០០(ម្ភៃលាន) រៀល ទៅ១០០ ០០០ ០០០(មួយរយលាន) រៀល ដោយ **ន.ធ.ក.** ចំពោះក្រុមហ៊ុនធានារ៉ាប់រងដែលមិនបានបង្កើនដើមទុនតាមចំនួនតម្រូវ តាមកាលកំណត់ ដូចមានចែងក្នុងប្រការ១២ នៃប្រកាសនេះ។

ត្រូវទទួលរងវិធានការរដ្ឋបាលដូចមានចែងក្នុងប្រការ២២ និង/ឬ ត្រូវផាកពិន័យជាប្រាក់ពី ១០ ០០០ ០០០(ដប់លាន) រៀល ទៅ ៥០ ០០០ ០០០(ហាសិបលាន) រៀល ដោយ **ន.ធ.ក.** ចំពោះក្រុមហ៊ុនធានារ៉ាប់រងដែលយឺតយ៉ាវក្នុងការបង្កើនដើមទុនតាមចំនួនតម្រូវចាប់ពី ១(មួយ) ថ្ងៃ ដល់ ៣០(សាមសិប) ថ្ងៃ។ ក្នុងករណីយឺតយ៉ាវមានរយៈពេលលើសពី ៣០ (សាមសិប) ថ្ងៃ ក្រុមហ៊ុនត្រូវទទួលការផាកពិន័យជាប្រាក់ចំនួនទ្វេដងនៃប្រាក់ផាកពិន័យលើកមុន។

**ប្រការ២៦ ._**

ត្រូវទទួលរងវិធានការរដ្ឋបាលដូចមានចែងក្នុងប្រការ២២ និង/ឬ ត្រូវផាកពិន័យជាប្រាក់ពី ២០ ០០០ ០០០(ម្ភៃលាន) រៀល ទៅ១០០ ០០០ ០០០(មួយរយលាន) រៀល ដោយ **ន.ធ.ក.** ចំពោះក្រុមហ៊ុន

ធានារ៉ាប់រងដែលមិនបានបង្កើនដើមទុនផ្ទាល់របស់ម្ចាស់ហ៊ុន តាមកាលកំណត់ ដូចមានចែងក្នុងប្រការ១៦ នៃប្រកាសនេះ។

ត្រូវទទួលរងវិធានការរដ្ឋបាលដូចមានចែងក្នុងប្រការ២២ និង/ឬ ត្រូវផាកពិន័យជាប្រាក់ពី ១០ ០០០ ០០០(ដប់លាន) រៀល ទៅ ៥០ ០០០ ០០០(ហាសិបលាន) រៀល ដោយ **ន.ធ.ក.** ចំពោះក្រុមហ៊ុនធានារ៉ាប់រងដែលយឺតយ៉ាវក្នុងការបង្កើនដើមទុនផ្ទាល់របស់ម្ចាស់ហ៊ុន ចាប់ពី ១ (មួយ) ថ្ងៃ ដល់ ៣០ (សាមសិប) ថ្ងៃ។ ក្នុងករណីយឺតយ៉ាវមានរយៈពេលលើសពី ៣០(សាមសិប) ថ្ងៃ។ ក្រុមហ៊ុនត្រូវទទួលការផាកពិន័យជាប្រាក់ចំនួនទ្វេដងនៃប្រាក់ផាកពិន័យលើកមុន។

**ប្រការ២៧ .-**

ត្រូវទទួលរងវិធានការរដ្ឋបាលដូចមានចែងក្នុងប្រការ២២ និង/ឬ ត្រូវផាកពិន័យជាប្រាក់ពី ១០ ០០០ ០០០(ដប់លាន) រៀល ទៅ ២០ ០០០ ០០០(ម្ភៃលាន) រៀល ដោយ **ន.ធ.ក.** ចំពោះក្រុមហ៊ុនធានារ៉ាប់រងដែលមិនបានសុំការអនុញ្ញាតជាមុនពី **ន.ធ.ក.** លើការបែងចែកភាគលាភជូនភាគទុនិកដូចមានចែងក្នុងប្រការ១៧ នៃប្រកាសនេះ។

**ប្រការ២៨ .-**

ត្រូវទទួលរងវិធានការរដ្ឋបាលដូចមានចែងក្នុងប្រការ២២ និង/ឬ ត្រូវផាកពិន័យជាប្រាក់ពី ៥ ០០០ ០០០(ប្រាំលាន) រៀល ទៅ ២០ ០០០ ០០០(ម្ភៃលាន) រៀល ដោយ **ន.ធ.ក.** ចំពោះក្រុមហ៊ុនធានារ៉ាប់រងដែលមិនផ្តល់របាយការណ៍ប្រចាំខែ,របាយការណ៍ប្រចាំត្រីមាស និងរបាយការណ៍ប្រចាំឆ្នាំ ដូចមានចែងក្នុងប្រការ១៩ ឬប្រការ២០ ឬប្រការ២១ នៃប្រកាសនេះ។ ក្នុងករណីយឺតយ៉ាវមានរយៈពេលលើសពី ៣០(សាមសិប) ថ្ងៃ ក្រុមហ៊ុនត្រូវទទួលការផាកពិន័យជាប្រាក់ចំនួនទ្វេដងនៃប្រាក់ផាកពិន័យលើកមុន។

**ប្រការ២៩ .-**

ក្រុមហ៊ុនធានារ៉ាប់រងទាំងឡាយណាដែលធ្លាប់ទទួលការផាកពិន័យអន្តរការណ៍ម្តងរួចហើយ ប៉ុន្តែនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែល ក្រុមហ៊ុនត្រូវទទួលការផាកពិន័យជាប្រាក់ចំនួនទ្វេដងនៃទឹកប្រាក់ផាកពិន័យលើកមុន និង/ឬត្រូវទទួលវិធានការរដ្ឋបាលដូចមានចែងក្នុងប្រការ២២ នៃប្រកាសនេះ។

**ប្រការ៣០ .-**

បទប្បញ្ញត្តិនៃជំពូកទោល(បទប្បញ្ញត្តិទូទៅ) នៃមាតិកាទី១(បទប្បញ្ញត្តិទូទៅ) និងជំពូកទោល(ការបង្ខំដល់រូបកាយ) នៃមាតិកាទី៣ (ការបង្ខំដល់រូបកាយ) នៃគន្ថីទី៨នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវយកមកអនុវត្តក្នុងករណីដែលសេចក្តីសម្រេចអំពីការផាកពិន័យបានចូលជាស្ថាពរ។

**ប្រការ៣១ .-**

បែបបទ និងនីតិវិធីនៃការចាត់វិធានការរដ្ឋបាល និងការដាក់ពិន័យដូចមានចែងក្នុងជំពូកនេះ ត្រូវកំណត់ដោយ **ន.ធ.ក.**។

**ប្រការ៣២ .-**

បុគ្គលដែលរងឥទ្ធិពលដោយផ្ទាល់ពីសេចក្ដីសម្រេចរបស់ **ន.ធ.ក.** ដូចមានចែងក្នុងជំពូកនេះ អាចប្ដឹងតវ៉ាតាមនីតិវិធីដូចមានចែងក្នុងច្បាប់ស្ដីពីការធានារ៉ាប់រង។

**ប្រការ៣៣ .-**

វិធានការរដ្ឋបាលនិងការដាក់ពិន័យដូចមានចែងក្នុងជំពូកនេះ មិនរារាំងការអនុវត្តច្បាប់ព្រហ្មទណ្ឌជាធរមាន និងដោយមិនទាន់គិតដល់សំណងនៃការខូចខាតផ្សេងទៀត។

## ជំពូកទី៦

## អន្តរប្បញ្ញត្តិ

**ប្រការ៣៤ .-**

ក្រុមហ៊ុនធានារ៉ាប់រងទូទៅ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត និងក្រុមហ៊ុនធានារ៉ាប់រងបន្ត ដែលកំពុងធ្វើប្រតិបត្តិការអាជីវកម្មក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញបង្គ្រប់កម្រិតសាធនភាព និងដើមទុនអនុលោមតាមបទប្បញ្ញត្តិនេះ ក្នុងរយៈពេលយ៉ាងយូរ ៦ (ប្រាំមួយ)ខែ ចាប់ពីថ្ងៃដែលប្រកាសនេះចូលជាធរមាន។

ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចដែលកំពុងធ្វើប្រតិបត្តិការអាជីវកម្មក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញបង្គ្រប់កម្រិតសាធនភាព និងដើមទុនអនុលោមតាមបទប្បញ្ញត្តិនេះ ក្នុងរយៈពេលយ៉ាងយូរ ១ (មួយ) ឆ្នាំ ចាប់ពីថ្ងៃដែលប្រកាសនេះចូលជាធរមាន។

**ប្រការ៣៥ .-**

ក្រុមហ៊ុនធានារ៉ាប់រងទូទៅ និងក្រុមហ៊ុនធានារ៉ាប់រងបន្តចំពោះការធានារ៉ាប់រងទូទៅ ដែលកំពុងធ្វើប្រតិបត្តិការអាជីវកម្មក្នុងព្រះរាជាណាចក្រកម្ពុជា និងមានទិន្នន័យតិចជាង ៣ (បី)ឆ្នាំ ត្រូវគណនាសាធនភាពតម្រូវ ដោយប្រើប្រាស់ទិន្នន័យដែលក្រុមហ៊ុនមាន ចំពោះវិធីសាស្ត្រសំណងធានារ៉ាប់រងសុទ្ធ។

## ជំពូកទី៧

## អវសានប្បញ្ញត្តិ

**ប្រការ៣៦ .-**

អគ្គនាយកនៃ **ន.ធ.ក.** អាចចេញគោលការណ៍ណែនាំ អនុលោមតាមច្បាប់ស្ដីពីការធានារ៉ាប់រង អនុក្រឹត្យស្ដីពីការធានារ៉ាប់រង និងប្រកាសនេះដើម្បីសម្រួលដល់ការយល់ដឹង និងការអនុវត្តតាមប្រកាសនេះ។

**ប្រការ៣៧ ._**

ប្រកាសលេខ ១៨៦ សហវ.ប្រក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៧ ស្តីពីកម្រិតសាធនភាពសម្រាប់ក្រុមហ៊ុនធានារ៉ាប់រងទូទៅ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣៨ ._**

អគ្គនាយកនៃ **ន.ធ.ភ.** ប្រធាននាយកដ្ឋានត្រួតពិនិត្យ គ្រប់ប្រធាននាយកដ្ឋានស្ថិតនៅចំណុះឱ្យ **ន.ធ.ភ.** និងបុគ្គលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ តាមភារកិច្ចរៀងខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ពុធ ៦ រោច ខែ មិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ឯកឧត្តម លោកជំទាវជាអនុប្រធាន និងសមាជិកក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៣៨
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ